# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ

## ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករ-និយោជិត

## នៅក្នុងក្រុមហ៊ុនធី&ខេ ហ្គាមេន អ៊ីដាស្ត្រី ខូអិលធីឌី

នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣ វេលាម៉ោង០៩និង០៥នាទី នៅក្នុងក្រុមហ៊ុនធី&ខេ ហ្គាមេន អ៊ិនដាស្ទ្រី ខូអិលធីឌី ដែលមានអាស័យដ្ឋានស្ថិតនៅភូមិទួលពង្រ សង្កាត់ចោមចៅ១ ខ័ណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ មានការប្រជុំមួយស្តីអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ-និយោជិត ។

### ១. សមាសភាពអ្នកចូលរួម

#### ក. ភាគីក្រុមហ៊ុន

| | | |
|---|---|---|
| -លោកស្រី | សួង សោភ័ណ្ឌ | ប្រធានរដ្ឋបាល |
| -លោកស្រី | ប៊ូ រតនា | លេខាកត់ត្រា |

#### ខ. ភាគីខាងកម្មករ និយោជិត

-សហជីពប្រចាំមូលដ្ឋាន

-តំណាងកម្មករនិយោជិត ប្រតិភូបុគ្គលិកពេញសិទ្ធិ សហជីពមានបញ្ជីការ និងសហជីពមានភាពជាតំណាងបំផុត

### ២ ខ្លឹមសារអង្គប្រជុំ

ក្រោយការរាតត្បាតរបស់ជំងឺកូវីត-១៩រហូតមកដល់បច្ចុប្បបានធ្វើឲ្យក្រុមហ៊ុនបានជួបប្រទះវិបត្តិក្នុងដំណើរការផលិតកម្មយ៉ាងធ្ងន់ធ្ងរហើយសំខាន់ទៅទៀតនោះគឺក្រុមហ៊ុនពុំមានការបញ្ជាទិញដែលជាហេតុផលចាំបាច់តម្រូវឲ្យមានមានការព្យួរកិច្ចសន្យាការងារមួយរយៈពេល ។

### ៣.លទ្ធផលអង្គប្រជុំ

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយសន្តិវិធីនិងប្រកបដោយការយោគយល់គ្នាតាមស្ថានភាពជាក់ស្តែង ដោយទាំងភាគីខាងក្រុមហ៊ុន និងសហជីពប្រចាំមូលដ្ឋានតំណាងកម្មករនិយោជិតប្រតិភូបុគ្គលិកពេញសិទ្ធិ សហជីពមានបញ្ជីការ និងសហជីពមានភាពជាតំណាងបំផុត បានព្រមព្រៀងគ្នាតាមលក្ខខណ្ឌដូចខាងក្រោមៈ

១-ក្រុមហ៊ុននឹងព្យួរកិច្ចសន្យាការងារកម្មករ-និយោជិតផ្នែកបង្ហើយការ ផ្នែកឃ្លាំងចំនួន២៧១នាក់ ស្រី២៣១នាក់ក្នុងចំណោមកម្មករ-និយោជិតសរុបចំនួន៨៩១នាក់ស្រី៧៤៨នាក់ ដោយគិតចាប់ពីថ្ងៃទី០៨ ខែមេសាឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ។

២-ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតចំនួន៣០ដុល្លារក្នុង១ខែ អំឡុងពេលព្យួរកិច្ចសន្យាការងារ ។

៣-ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភផ្តាច់ជូនកម្មករ-និយោជិតម្នាក់ៗ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារចំនួន៦០ដុល្លារ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ។

Scanned with CamSc

៤-ក្នុងករណីដែលក្រុមហ៊ុនមានភាពប្រសើរឡើងវិញ ហើយមានការងារធ្វើក្នុងកំឡុងពេលព្យួរនោះ ក្រុមហ៊ុននឹងអនុញ្ញាតិអោយកម្មករ-និយោជិតចូលធ្វើការមុនពេលកំណត់ ។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១០និង២០នាទីព្រឹកនាថ្ងៃដដែលក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខា រឺស្នាមមេដៃក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

ថ្ងៃចន្ទ ១៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ត្រូវនឹងថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣

**ស្នាមមេដៃ**

**តំណាងសហជីព តំណាងកម្មករ**

**ហត្ថលេខា**

**ប្រធានរដ្ឋបាល**

**ហត្ថលេខា**

**លេខាកត់ត្រា**